ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តុលាការកំពូល

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥៤

ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០

**សាលដីកា**

លេខ ១០៦ “III”

ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២

ដោយអង្គជំនុំជម្រះមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោ[redacted]ហ៊ុំងតីយ និងឈ្មោះ[redacted]ហ៊ុំងទឹង ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៥ ក្រV “សស” ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ ៖**

១-ឈ្មោះ[redacted]យ៉ាំងឌីង ភេទប្រុស អាយុ ៣២ ឆ្នាំ ជនជាតិវៀតណាម មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅស្រុកពញាឮ ខេត្តកណ្តាល មានលំនៅបច្ចុ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]“ស” ម្តាយឈ្មោះ[redacted]ស” ប្រពន្ធឈ្មោះ[redacted] មានកូន ០២ នាក់ ។ ទោសពីមុនគ្មាន ។ ជានីតិជន ។



Scanned with CamScanner

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៦៤៥ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ។

២-ឈ្មោះ[redacted] **យ៉ាំងតឺយ** ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិវៀតណាម មុខរបរចិញ្ចឹមត្រី មានទីកន្លែងកំណើតនៅខេត្តកំពង់ឆ្នាំង មានលំនៅ[redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]"ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ[redacted] មានកូន ០២ នាក់។ ទោសពីមុនគ្មាន។ ជាទីតិជន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៦៤៦ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ។

-លោក[redacted] សង្ឃមន្និ , [redacted] បូរ៉ា, [redacted] សុវិន ជាមេធាវីការពារសិទ្ធិ ។

**ជាប់ចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ បុរីប៊ុនជេស៍ ភូមិដូង មណ្ឌល៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**<u>អំពីអង្គហេតុ៖</u>**

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ ឆ្នាំ២០១២ វេលាម៉ោង ១៤ និង ៣០ នាទី នៅចំណុចបន្ទប់ផ្ទះគ្មានលេខ បុរីប៊ុនជេស៍ ភូមិដូង មណ្ឌល៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ មានករណីជួញដូរគ្រឿងញៀនដោយខុសច្បាប់ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted] យ៉ាំងតឺយ ភេទប្រុស អាយុ ៤០ ឆ្នាំ និងឈ្មោះ[redacted]យ៉ាំងទឹង ភេទប្រុស អាយុ ៣៧ ឆ្នាំ ។ នៅថ្ងៃកើតហេតុឈ្មោះ[redacted]យ៉ាំងតឺយ បាននាំម៉ូយមកទិញគ្រឿងញៀន (កម្លាំងសម្ងាត់) ទៅរង់ចាំទិញថ្នាំញៀន នៅក្នុងផ្ទះគ្មានលេខ ផ្លូវបេតុង បូរីប៊ុនជេស៍។ នៅខណៈពេលរង់ចាំបានមួយសន្ទុះក្រោយមក ស្រាប់តែឈ្មោះ [redacted]យ៉ាំងទឹង បានជិះម៉ូតូមួយគ្រឿងមកដល់ ហើយប្រគល់គ្រឿងញៀនដែលបានដាក់ក្នុងកាបូបស្ពាយ រួចហុចទៅឱ្យឈ្មោះ[redacted] យ៉ាំងតឺយ ដើម្បីប្រគល់ឱ្យម៉ូយដែលបញ្ជាទិញនោះ ។ នៅពេលកំពុងធ្វើសកម្មភាពជួញដូរ ក៏ត្រូវកម្លាំងសមត្ថកិច្ចចុះបង្ក្រាបធ្វើការឃាត់ខ្លួនជាក់ស្ដែង រួមជាមួយវត្ថុតាងគ្រឿងញៀនចំនួន ០៣ ដុំ មានទម្ងន់សរុប ១០៤៩,៣៩ ក្រាម ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៩៥ក្រ១ "ង"ភ.ព.ព្រ.១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ផ្ដន្ទាទោស ៖

ក[redacted] យ៉ាំងទឹង ភេទប្រុស អាយុ ៣២ ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ (ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០.០០០.០០០ រៀល (ហុកសិបលាន)រៀល ។

[redacted] យ៉ាំងតឺយ ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ (ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០.០០០.០០០ រៀល (ហុកសិបលាន)រៀល ។



Scanned with CamScanner

ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ក្នុងបុរីប៉ុនជេស ភូមិដូង មណ្ឌល៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យកដែលត្រូវរឹបអូសមាន៖

-ស្រោមសំបុត្រពណ៌លឿងបិតស្កុតជិត មានចុះហត្ថលេខាមន្ត្រីជំនាញ និងស្នាមមេដៃជនសង្ស័យឈ្មោះ [redacted] យ៉ាំងទឹង , ឈ្មោះ[redacted]យ៉ាំងតីយ និងមានប្រថាប់ត្រាមន្ទីរប្រឆាំងគ្រឿងញៀន ដោយសរសេរដាក់ថា វត្ថុតាងគ្រឿងញៀន ពណ៌សទម្ងន់ ១០៤៩,៣៩ (មួយពាន់សែសិបប្រាំបួន ក្បៀសសាមសិបប្រាំបួន)ក្រាម ចំនួន ០១ ។

៣-វត្ថុចាប់យកដែលត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ៖

ក.ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល ២០៦ ចំនួន ០១ គ្រឿង ។

ខ.ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល C5-03 ចំនួន ០១ គ្រឿង ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិជនជាប់ចោទ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ។

រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៧៦១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted]យ៉ាំងទឹង ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩៥ ក្រ១ "ង" ភ.ព.ព្រ.ទ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៧៦២ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ របស់ជនជាប់ចោទ ឈ្មោះ[redacted]យ៉ាំងតីយ ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩៥ ក្រ១ "ង" ភ.ព.ព្រ.ទ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៥ ក្រVb "សស" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៧៦១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] យ៉ាំងទឹង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៧៦២ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted]យ៉ាំងតីយ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៩៥ ក្រ១ "ង" ភ.ព.ព្រ.ទ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការទាំងមូលដដែល ។



Scanned with CamScanner

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឹយ និ[redacted] យ៉ាំងទឹង ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៥ ក្រVប "សស" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោ[redacted] យ៉ាំងតឹយ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted] យ៉ាំងទឹង។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍ឡើងធ្វើសេចក្តីរាយការណ៍ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា សាលាដំបូងរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted] យ៉ាំងទឹង និងឈ្មោះ [redacted] យ៉ាំងតឹយ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។ ពីព្រោះថាជនជាប់ចោទទាំងពីរនាក់បានសារភាពនៅគ្រប់ដំណាក់កាលស៊ើបសួរនិងនៅពេលសវនាការផងដែរ ។ ហើយការឃាត់ខ្លួនជនជាប់ចោទ គឺនៅពេលដែលកំពុងធ្វើសកម្មភាពលក់ដូរនិងដឹកជញ្ជូនគ្រឿងញៀន ជាបទល្មើសជាក់ស្តែង ព្រមទាំងដកហូតនូវវត្ថុតាងជាសារធាតុញៀនមានទម្ងន់សរុប ១០៤៩,៩៤ ក្រាម មានបរិមាណមេតំហ្វេតាមីនសុទ្ធសរុប ១០៤៩,៣៩ក្រាម x (គុណ)៥១,៩៣ = ៥៤៤,៩៤ ក្រាម ដែលស្ថិតនៅក្នុងតារាងទី១ កថាខណ្ឌទី៤ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត ។ ជនជាប់ចោទទាំងពីរនាក់សុំបន្ធូរបន្ថយទោសចំណុចនេះពុំគប្បីបន្ធូរបន្ថយទោសដល់ជនជាប់ចោទនោះឡើយ ។ ហេតុដូចនេះសូមប្រធានក្រុមប្រឹក្សាសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល។

-លោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted] យ៉ាំងតឹយ បានធ្វើសេចក្តីសន្និដ្ឋានថា ការដែលជនជាប់ចោទបានប្តឹងសាទុក្ខមកតុលាការកំពូល ពីព្រោះដើម្បីស្នើសុំឱ្យតុលាការកំពូលបន្ធូរបន្ថយទោសឱ្យ ដោយសាលាដំបូងរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍ភ្នំពេញពុំបានពិចារណាលើស្ថានសម្រាលទោសទេ ។ បើពិចារណាលើអង្គហេតុតាំងពីដំបូង [redacted] យ៉ាំងតឹយ បានចាញ់បោកឈ្មោះ យ៉ាង ដោយមិនបានដឹងថា ក្នុងកាបូបមានថ្នាំញៀននោះទេ ។ កត្តាដែលធ្វើឱ្យជនជាប់ចោទ [redacted] យ៉ាំងតឹយ បានចាញ់បោកឈ្មោះ យ៉ាង គឺមកពីកត្តាជីវភាព ដោយសារតែក្នុងអំឡុងពេលនោះត្រូវការលុយដើម្បីទិញទឹកដោះគោឱ្យកូនដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងមួយទៀត គឺកត្តាភាពល្ងង់ខ្លៅដែលលោភលន់ចង់បានលុយ ក៏ជួយកាន់កាបូបនោះឱ្យឈ្មោះ សឹង ក៏ត្រូវបានសមត្ថកិច្ចឆែកឆេរឃាត់ខ្លួនតែម្តង ។ ជនជាប់ចោទឈ្មោះ[redacted] យ៉ាំងតឹយ បានសហការណ៍ជាមួយប៉ូលីស បានប្រាប់ថាយកពីឈ្មោះ យ៉ាង ។ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការជួញដូរគ្រឿងញៀន ធាតុសត្យានុម័តនិងធាតុអត្តនោម័ត គឺមិនមាននោះទេ ដោយជនជាប់ចោទមិនមានគម្រោង មិនមានចេតនាទុច្ចរិតក្នុងការជួញដូរសារធាតុញៀននោះទេ ប៉ុន្តែធាតុនីត្យានុកូលមានព្រោះជាបទល្មើសជាក់ស្តែង ។



Scanned with CamScanner

សំណូមពរ សូមស្នើសុំប្រធានក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោស តាមការស្នើសុំរបស់ជនជាប់ចោទ និងស្នើសុំបន្ថយសំណងពិន័យជាប្រាក់មកនៅត្រឹមពាក់កណ្តាល ។

-លោក [redacted] សង្ឃមន្នី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្[redacted]យ៉ាំងតឹយ បានធ្វើសេចក្តីសន្និដ្ឋានថា ការដែលកូនក្តីខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ពីព្រោះមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ គឺផ្អែកលើពាក្យសុំ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ចុះចាត់របៀប និងពាក្យសុំកោះហៅសាក្សីឈ្មោះ [redacted] សំណាង និងឈ្មោះ យ៉ាង មកចូលសវនាការ តែត្រូវបានសាលាឧទ្ធរណ៍លើកចោលពុំលើកយកមកពិចារណាទេ ។ សាលាដំបូងរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍ភ្នំពេញមិនបានអនុវត្តតាមមាត្រា ៧១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលច្បាប់តម្រូវឱ្យតុលាការកោះហៅនិងស្តាប់ចម្លើយ ដែលជាការបំពានច្បាប់និងការអនុវត្តខុស ដែលជាមូលហេតុដែលស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ម្យ៉ាងទៀត កូនក្តីខ្លួនគ្រាន់តែជាបុគ្គលដែលគេប្រើឱ្យយកគ្រឿងញៀនឱ្យគេបន្ត ហើយមានកម្រៃបន្តិចបន្តួចប៉ុណ្ណោះ ដោយសារតែមានជីវភាពខ្វះខាតនិងខ្វះការពិចារណា ទើបធ្វើឱ្យឈ្មោ[redacted]សំណាង និងឈ្មោះ យ៉ាង ដែលជាមេក្លោងឱ្យប្រព្រឹត្តបទល្មើសបាន ។ មួយទៀត ជនជាប់ចោទបានសហការណ៍ជាមួយសមត្ថកិច្ចដែលអាចចង្អុលបង្ហាញជនល្មើសដែលជាមេក្លោងរហូតដល់ចាប់ខ្លួនឈ្មោ[redacted]សំណាង និងឈ្មោះ យ៉ាង បាន ។ សាលាឧទ្ធរណ៍ភ្នំពេញពុំបានផ្តល់ស្ថានសម្រាល តាមមាត្រា ៣២ នៃច្បាប់ស្តីពីការជួញដូរគ្រឿងញៀន ដែលបានចែងថា ចារី សហចារី អ្នកសមគំនិត និងអ្នកផ្តើមគំនិត ដែលបានរាយការណ៍អំពីអត្តសញ្ញាណអ្នកចូលរួមដទៃទៀតមុនពេលដែលខ្លួនត្រូវបានចោទប្រកាន់ ឬដែលបានជួយសម្រួលឱ្យមានការចាប់ខ្លួនជនដទៃទៀត ក្រោយពេលដែលខ្លួនត្រូវបានចោទប្រកាន់ ត្រូវបន្ថយទោស ។ កូនក្តីខ្លួនគួរតែទទួលបាននូវស្ថានសម្រាល ។

សំណូមពរ សូមប្រធានក្រុមប្រឹក្សាមេត្តាពិចារណាបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ និងបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ភ្នំពេញដើម្បីជំនុំជម្រះសាជាថ្មី ។

-លោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទឹង និងឈ្មោ[redacted]យ៉ាំងតឹយ បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនសូមឯកភាពតាមសហភាគារបស់ខ្លួននិងស្នើសុំឱ្យមានការបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ។ នៅក្នុងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់សាលដីការបស់សាលាដំបូងរាជធានីភ្នំពេញ ដោយដាក់ពន្ធនាគារកំណត់ ២៥ (ម្ភៃប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ ៦០.០០០.០០០ (ហុកសិបលាន) រៀល។

-ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

### តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ុងតីយ និងឈ្មោះ [redacted] យ៉ុងទីង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្ដីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការនិងមាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នាពេលសវនាការមេធាវីការពារជនជាប់ចោទបានលើកឡើងថា ៖

ក-ស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យដល់ជនជាប់ចោទ ដោយហេតុថា ជនជាប់ចោទបានចាញ់បោកឈ្មោះ យ៉ាង ដោយមកពីមានជីវភាពក្រីក្រ មានជនមានភាពល្ងង់ខ្លៅ ការប្រព្រឹត្តរបស់ជនជាប់ចោទមិនមានធាតុផ្សំអត្តនោម័ត តែខ្លួនទទួលស្គាល់ថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានធាតុផ្សំសត្យានុម័តនៃបទល្មើស ដូច្នេះខ្លួនស្នើសុំឱ្យតុលាការកំពូលសម្រេចបន្ធូរបន្ថយទោសលើជនជាប់ចោទមកនៅត្រឹមកម្រិតពាក់កណ្ដាលនៃទោស ទាំងទោសដាក់ពន្ធនាគារ ទាំងទោសពិន័យជាប្រាក់ នោះតុលាការកំពូលពិចារណាឃើញថា ជាសេចក្ដីសន្និដ្ឋានមិនមានមូលដ្ឋានសំអាងលើអង្គហេតុ ភស្ដុតាង និងអង្គច្បាប់ត្រឹមត្រូវនោះទេ សេចក្ដីសន្និដ្ឋានរបស់មេធាវីមិនបានលើកឡើងអំពីមូលដ្ឋានពីអង្គហេតុ ភស្តុតាង ពីស្ថានភាពទាំងឡាយដូចមានបញ្ញត្តក្នុងមាត្រា ៣២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ទេ ។ ជនជាប់ចោទទាំងពីរនាក់បានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មានធាតុសុទ្ធនៃសារធាតុញៀនប្រភេទម្សៅហេរ៉ូអ៊ីនមានទម្ងន់រហូតដល់ទៅ ៥៤៤,៨៤ ក្រាម ឯណោះ តែតុលាការអង្គហេតុបានផ្ដល់នូវស្ថានសម្រាលដូចបានលើកឡើងក្នុងផ្នែកសំអាងហេតុ ត្រង់ចំណុចទី៩ និងទី១០ នៃសាលក្រមសាលាដំបូងរាជធានីភ្នំពេញលេខ ៣៩៥ ក្រ១ "ង" ភ.ព.ព្រ.ទ. ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ដល់ជនជាប់ចោទទាំងពីរនាក់រួចហើយ ។

ខ-សាលាឧទ្ធរណ៍ភ្នំពេញពុំបានពិចារណាមាត្រា ៣២ ស្ដីពីការសម្រាលទោស ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន នោះតុលាការកំពូលពិនិត្យ ពិចារណាឃើញថា ពុំមានភស្ដុតាងបញ្ជាក់ថា ជនជាប់ចោទបានរាយការណ៍ឲ្យស្គាល់អំពីអត្តសញ្ញាណអ្នកចូលរួមដទៃទៀតមុនពេលខ្លួនបានត្រូវចោទប្រកាន់ ឬដែលបានជួយសម្រួលឲ្យមានការចាប់ខ្លួនជនដទៃទៀតក្រោយពេលដែលខ្លួនត្រូវបានចោទប្រកាន់នោះឡើយ ។ការដែលមេធាវីការពារជនជាប់ចោទបានអះអាងថា ជនជាប់ចោទបានសហការណ៍ជាមួយសមត្ថកិច្ចឈានដល់ការចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សំណាង នោះពុំមានភស្ដុតាងបញ្ជាក់ឡើយ ដោយហេតុថា ចម្លើយជនជាប់ចោទនៅសមត្ថកិច្ចនគរបាលយុត្តិធម៌ នៅអយ្យការ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ នាសវនាការសាលាដំបូងរាជធានីភ្នំពេញ និងសវនាការសាលាឧទ្ធរណ៍ភ្នំពេញ ពុំមានចម្លើយជនជាប់ចោទឆ្លើយទាក់ទងនឹងឈ្មោះ [redacted] សំណាង នេះទេ

គ-ការដែលមេធាវីការពារជនជាប់ចោទបានលើកឡើងសុំឱ្យតុលាការកំពូលសម្រេចបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ដោយគ្មានសិទ្ធិរបស់ខ្លួន នោះតុលាការកំពូលបានលើកមកបង្ហាញដូចមានក្នុងផ្នែកសំអាងហេតុដូចខាងលើនេះហើយ ។



Scanned with CamScanner

ឃ-សារណាបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាំងពីរនាក់ដែលបានលើកឡើង ថា ខ្លួនបានទទួលការអប់រំកែប្រែខ្លួននៅក្នុងមណ្ឌលអប់រំកែប្រែទី១ បានដឹងពីកំហុសនិងបានកែប្រែខ្លួន គោរពបទបញ្ជា ចូលរួមហាត់ប្រាណ ធ្វើពលកម្ម គោរពបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល បានសារភាពនូវកំហុសរបស់ខ្លួន និងសុំឱ្យតុលាការបន្ធូរបន្ថយទោស នោះតុលាការកំពូលពិចារណាឃើញថា វាពុំមែនជាមូលហេតុដែលនាំឱ្យតុលាការសម្រេចផ្តល់នូវស្ថានសម្រាលទោសដល់ជនជាប់ចោទទេ ស្ថានភាពដែលជនជាប់ចោទទាំងពីរនាក់បានលើកឡើងទាំងនេះ វាអាចជាមូលហេតុដែលឱ្យមានការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ដែលជាវិធានការយុត្តិធម៌សម្រាប់អនុវត្តចំពោះទណ្ឌិតក្នុងអំឡុងពេលអនុវត្តទោស តាមអំណាចសាលក្រមសាលដីកាដែលជាសមត្ថកិច្ចរបស់ស្ថាប័នផ្សេង ពុំមែនតុលាការទេ ។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សររបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា ៖

-បណ្តឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឺយ និងឈ្មោះ [redacted] យ៉ាំងទឹង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-សាលាដំបូងនិងសាលាឧទ្ធរណ៍បានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឺយ និងឈ្មោះ [redacted] យ៉ាំងទឹង គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ពីព្រោះជនជាប់ចោទទាំងពីរនាក់បានសារភាពនៅគ្រប់ដំណាក់កាលនីតិវិធីស៊ើបសួរនិងសវនាការ ។ ការចាប់ឃាត់ខ្លួនជនជាប់ចោទគឺនៅខណៈពេលកំពុងប្រព្រឹត្តសកម្មភាពលក់ដូរ និងដឹកជញ្ជូនគ្រឿងញៀន ជាបទល្មើសជាក់ស្តែង ព្រមទាំងដកហូតនូវវត្ថុតាងជាសារធាតុមានទម្ងន់សរុប ១០៤៩,៨៤ ក្រាម មានបរិមាណមេតំហ្វេតាមីនសុទ្ធទម្ងន់ ៥៤៤,៨៤ ក្រាម ដែលស្ថិតនៅក្នុងតារាងទី១ កថាខណ្ឌទី៤ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត ។ ជនជាប់ចោទទាំងពីរនាក់បានសុំបន្ធូរបន្ថយទោស ចំណុចនេះតុលាការពុំគប្បីបន្ធូរបន្ថយទោសឱ្យ ជនជាប់ចោទនោះទេ ។ និង

-ប្តឹងសុំតុលាការកំពូលសម្រេចបណ្តឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឺយ និងឈ្មោះ [redacted] យ៉ាំងទឹង និងសុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៥ ក្រV "សស" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ។

នោះតុលាការកំពូលពិនិត្យ ពិចារណាឃើញថា គឺជាសេចក្តីសន្និដ្ឋានមានមូលដ្ឋានសំអាងលើអង្គហេតុភស្តុតាង និងអង្គច្បាប់ត្រឹមត្រូវ ហើយក៏សមស្របទៅនឹងផ្នែកសំអាងហេតុ ត្រង់ចំណុចផ្សេងទៀតរបស់តុលាការកំពូលដែរ ។

៤-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឺយ និងឈ្មោះ [redacted] យ៉ាំងទឹង ធ្វើឡើងមិនមានមូលហេតុនៃបណ្តឹងសាទុក្ខដូចមានបញ្ញត្តក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។



Scanned with CamScanner

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៥ក្រV “សស” ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមច្បាប់ ។

**ហេតុដូច្នេះ**

**សម្រេចសេចក្ដី**

**១-បដិសេធ**បណ្ដឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឹយ និងឈ្មោះ [redacted] យ៉ាំងទឹង ។

**២-តម្កល់**សាលដីកាព្រហ្មទណ្ឌលេខ ២៥ក្រV “សស” ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| ឯកឧត្ដម | [redacted] | ជាប្រធាន |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម។

**បានឃើញ**

ថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]

ថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner